ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ២

បញ្ជីសំណួរសម្រាប់ធ្វើការសម្ភាសន៍ប្រជាពលរដ្ឋដែលរងផលប៉ះពាល់
ពីគម្រោង

កម្រងសំណួរសំរាប់ការខាតម្លៃនៅលើផលប៉ះពាល់សង្គម របស់អ្នកភូមិ ដែលរស់នៅតំបន់ជាប់ស្រឃាលនៃព្រៃសម្បទានខេត្ត ក្រចេះ

I. អត្តសញ្ញាណ និងទីតាំងភូមិសាស្ត្រ

1.1. ខេត្ត : .... លេខកូដ
1.2. ស្រុក : .... លេខកូដ
1.3. ឃុំ : .... លេខកូដ
1.4. ភូមិ : .... លេខកូដ
1.5. ឈ្មោះមេគ្រួសារ: នាមត្រកូល & នាម ....

II. ព័ត៌មានរបស់អ្នកតបសម្ភាសន៍

2.1. ឈ្មោះរបស់អ្នកតបសម្ភាសន៍ ....
2.2. អាយុ ....
2.3. ភេទ: 1. ប្រុស 2. ស្រី
2.4. ទំនាក់ទំនងជាមួយមេគ្រួសារ: 1. មេគ្រួសារ; 2. ប្រពន្ធ; 3. កូនប្រុស/កូនស្រី 4.ឪពុកម្តាយ
5. ផ្សេងៗ ....
2.5. ស្ថានភាពគ្រួសារ: 1. នៅលីវ; 2. រៀបការ; 3. មេម៉ាយ/ពោះម៉ាយ: 4. រស់នៅបែកគ្នា
5. ផ្សេងៗ (បញ្ជាក់) ....
2.6. កំរិតអប់រំខ្ពស់បំផុត: ....
2.7. ជនជាតិ: 1. ខ្មែរ; 2. ចាម; 3. វៀតណាម 4. ភ្នង; 5. ចាក៉យ
6. ផ្សេងៗ(បញ្ជាក់) ....
2.8. មុខរបរ: 1. កំពុងរៀន 2. ធ្វើការ 3. ធ្វើការខ្លួនឯង 4. ចូលនិវត្ត; 5. គ្មានការងារតែកំពុងស្វែងរក
6. ចាស់ពេកធ្វើការមិនកើត

____
Signature over Printed Name of Field Interviewer–Date
ហត្ថលេខា និងឈ្មោះអ្នកសម្ភាសន៍-កាលបរិច្ឆេទ

____
Signature of Reviewer/Supervisor – Date
ហត្ថលេខានៃអ្នកត្រួតពិនិត្យ/ប្រធានក្រុម-កាលបរិច្ឆេទ

III. ព័ត៌មានរបស់អ្នកបញ្ចូលទិន្នន័យ

3.1. ឈ្មោះ: ....
3.2. ថ្ងៃបញ្ចូល: ....
3.3. ការកត់សំគាល់: ....

IV. ព័ត៌មានប្រជាសាស្ត្រ - លក្ខណៈរបស់គ្រួសារ

4.1. តើមេគ្រួសារអាចសរសេរនិងអានភាសាណាមួយដែរ ឬទេ? 1. បាទ/ចាស 2. ទេ

4.2. តើគ្រួសាររបស់អ្នកមានសមាជិកប៉ុន្មាននាក់? ______________

([illegible])

4.3. តើមេគ្រួសារនេះជាមនុស្សស្រីមែន ឬទេ? 1. បាទ/ចាស 2. ទេ

4.4. តើមេគ្រួសារនេះជាជនពិការមែន ឬទេ? 1. បាទ/ចាស 2. ទេ

4.5. តើមេគ្រួសារនេះជាមនុស្សចាស់ជរាមែនឬទេ? (លើសពី៦៥ឆ្នាំឡើង) 1. បាទ/ចាស 2. ទេ

ចុះបញ្ជីអ្នកដែលរស់នៅក្នុងផ្ទះនេះ [illegible]		ទំនាក់ទំនងជាមួយមេគ្រួសារ ១ ប្រពន្ធ/ប្តី ២.កូន ៣ សាច់ញាតិ	ស្ថានភាពគ្រួសារ (ប្រើលេខកូដ)	អាយុ	ភេទ 1 ប្រុស 2 ស្រី	កំរិតការអប់រំ (ប្រើលេខកូដ)	តើគេនៅបន្តការសិក្សាឬទេ? 1 បាទ/ចាស (បន្តទៅ) 2 ទេ (Age 6-18)	ហេតុផលដែលគេមិនទៅរៀន? (ប្រើលេខកូដ) (Age 6-18)	តើគេកាន់សាសនាអ្វី? (ប្រើលេខកូដ)	តើអ្នកជាជនជាតិអ្វី? (ប្រើលេខកូដ)	[illegible]
ល.រ	ឈ្មោះ	4.6	4.7	4.8	4.9	4.10	4.11	4.12	4.13	4.14	[illegible]
1		មេគ្រួសារ									
2											
3											
4											
5											
6											
7											
8											
9											
10											
11											
12											
13											

លក្ខណៈរបស់គ្រួសារ (ក)

Household Members										[illegible]	[illegible]	[illegible]	[illegible]
ល.រ	ឈ្មោះ (ដែលចុះនៅក្នុង)	តើគ្រួសារអ្នកជាសមាជិកនៃអង្គការណាមួយមែន ឬទេ? (បើបាទ/ចាស សូមប្រាប់ឈ្មោះអង្គការនោះ សំរាប់អាយុ១៨ឡើង)	សមាជិកណាដែលពិការ 1.បាទ/ចាស (ប្រើលេខកូដ) 2.19	ប្រភពចំណូលទី១ (ប្រើលេខកូដ) បើអត់មានដាក់លេខ 0	ប្រភពចំណូលទី២ (ប្រើលេខកូដ) បើអត់មានដាក់លេខ 0	ប្រភពចំណូលទី៣ (ប្រើលេខកូដ) បើអត់មានដាក់លេខ 0	ចំនូលសរុបក្នុង១ខែ (សរសេរចំនួនទឹកប្រាក់)	ចំណាយសរុបក្នុងមួយខែសំរាប់គ្រួសារ?					
		4.16	4.17	4.20			4.21	4.22	4.23	4.24	4.25	4.26	
សម្រាប់សមាជិកគ្រួសារដែលមានអាយុ១៨ឆ្នាំ និងលើស១៨ឆ្នាំ													
1													
2													
3													
4													
5													
6													
7													
8													
9													
10													
11													
12													
13													

[illegible]	លេខកូដសម្រាប់ 4.7	លេខកូដសម្រាប់ 4.8	លេខកូដសម្រាប់ 4.10		លេខកូដសម្រាប់ 4.12	លេខកូដសម្រាប់ 4.13	លេខកូដសម្រាប់ 4.14
[illegible]	1. នៅលីវ 2. រៀបការ 3. មេម៉ាយ 4. នៅបែកគ្នា 5. នៅជាមួយគ្នា 6. លែងលះគ្នា	00. ក្មេងមានអាយុតិចជាង ១ឆ្នាំ 999. មិនដឹង	0. អត់បានរៀន 1. មុនមត្តេយ្យ 2. បឋមសិក្សា 3. បឋមសិក្សា 4. ចប់បឋម 5. អនុវិទ្យាល័យ 6. ចប់អនុវិទ្យាល័យ	7. វិទ្យាល័យ 8. ចប់វិទ្យាល័យ 9. បរិញ្ញាបត្រ 10. ក្រោយបរិញ្ញាបត្រ 11. រៀនគត់ 12. បណ្តុះវិជ្ជាជីវៈ 13. ផ្សេងៗ______	1. ក្មេងពេក/ចាស់ពេក 2. ធ្វើការ 3. ឈឺ 4. រៀបការហើយ 5. ខ្វះថវិកា 6. សាលានៅឆ្ងាយ 7. ផ្សេងៗ ______________	1. ពុទ្ធសាសនា 2. អ៊ីស្លាម 3. កាតូលិក 4. ផ្សេងៗ_____	1. ខ្មែរ 2. វៀតណាម 3. ចាម 4. ផ្សេងៗ លេខកូដសម្រាប់ 10 1. ចាកយ 2. ទំពូន 3. គ្រឹង 4. គ្រោល 5. ផ្សេងៗ

[illegible]	[illegible]	លេខកូដសម្រាប់ 4.20	លេខកូដសម្រាប់ 4.23	លេខកូដសម្រាប់ 4.24	លេខកូដសម្រាប់ 4.25
[illegible]	[illegible]	1. ការងារឯកជន 2. ការងាររដ្ឋ 3. ការងារផ្ទាល់ខ្លួន 4. ប្រាក់ពូលនិវត្ត.ប្រាក់គេផ្ញើជូន 5. កិច្ចសន្យា 6. ការនេសាទត្រី 7. ការធ្វើកសិកម្ម 8. ការលក់ដូរ 9. ផ្សេងៗ ______________	1. កសិកម្ម 2. ការនេសាទត្រី 3. រុក្ខាប្រមាញ់ 4. ការផលិត 5. ការសាងសង់ 6. ការជីករ៉ែ,ការកាប់យកថ្ម 7. អគ្គិសនី,ឧស្ម័ន, ទឹក 8. លក់ដុំ,និងរាយតាមកញ្ចប់ 9. ការដឹកជញ្ជូន 10. ហាងទំនិញ 11. ម្ហូបអាហារ 12. ផ្សេងៗ__________	1. ពេញម៉ោង 2. រយៈពេលខ្លី ឬតាមរដូវកាល ,ធ្វើជំនួយ/ការងារតាមពេលព្រឹក 3. គ្រប់ពេល ធ្វើការងារផ្សេងៗពីមួយថ្ងៃទៅមួយថ្ងៃឬមួយសប្តាហ៍ទៅមួយសប្តាហ៍	1. ជឿថាគ្មានការងារដែលចំនេះ 2. រង់ចាំលទ្ធផលការដាក់ពាក្យធ្វើការងារពីមុន 3. មានជម្ងឺ/អសមត្ថភាពបណ្តោះអាសន្ន 4. រង់ចាំការជួលម្តងទៀត 5. ក្មេងពេក/ចាស់ពេកក្នុងការធ្វើការងារ 6. កំពុងរៀន 7. ផ្សេងៗ__________

4.27	តើគ្រួសាររបស់អ្នកបានរស់នៅភូមិ/ឃុំនេះអស់រយៈពេលយូប៉ុនណាយហើយ?	____ ឆ្នាំ	
4.28.	ហេតុអ្វីបានជាគ្រួសារអ្នកមករស់នៅក្នុងភូមិនេះ? (ចំលើយច្រើន)	1. កើតនៅភូមិនេះ 2. ស្វែងរកដីសំរាប់ធ្វើការដាំដុះ 3. ស៊ីឈ្នួលដាំដុះ, កាប់ឈើ, អារឈើ 4. ធ្វើការងារផ្សេងៗ 5. កាប់ឈើ, លក់ឈើ, រករកធ្យូង 6. បរបាញ់សត្វ និងប្រមូលអនុផលព្រៃឈើ 7. នេសាទ 8. ទិញអនុផលព្រៃឈើ 9. ផ្សេងៗ(បញ្ជាក់)............................	
4.29.	តើគ្រួសាររបស់អ្នករស់នៅទីនេះជាអចិន្ត្រៃ ឬទេ?	1-. បាទ/ចាស	0-. ទេ
4.30.	តើគ្រួសាររបស់អ្នកមានធ្វើកសិកម្មពនេចរដែរ ឬទេ?	1-. បាទ/ចាស	0-. ទេ
4.31.	តើគ្រួសាររបស់អ្នកមានផ្ទះផ្ទាល់ខ្លួនដែរ ឬទេ?	1- បាទ/ចាស	0- ទេ
4.32.	តើផ្ទះរបស់អ្នកមានទំហំប៉ុន្មាន?	ប......m x ទ........m = ...m^2	
4.33.	ប្រភេទផ្ទះ: (ចំលើយតែមួយ)	ខ្ទមផ្ទាល់ដី	1
		ខ្ទមនៅផុតពីដី	2
		ផ្ទះឈើដំបូលក្បឿង/ហ្វីប្រូ	3
		ផ្ទះឈើដំបូលស្លឹក/សង្កសី	4
		ផ្ទះស្លឹក/សង្កសីដំបូលស្លឹក/សង្កសី	5
		ផ្សេងៗ (បញ្ជាក់)	6
4.34.	តើប្រភពទឹកសំរាប់បរិភោគចំបងរបស់អ្នកបានមកពីណា? (ចំលើយតែមួយ)	អណ្តូងស្នប់	1
		អណ្តូងមានការថែរក្សាអនាម័យល្អ	2
		អណ្តូងគ្មានការថែរក្សាអនាម័យ	3
		ទន្លេ, បឹង, អូរ, ព្រែក	4
		ទឹកភ្លៀង	5
		ប្រភពទឹកផ្សេងទៀត (បញ្ជាក់)........	6
4.35.	តើប្រភពទឹកសំរាប់ប្រើប្រាស់ចំបងរបស់អ្នកបានមកពីណា? (ចំលើយតែមួយ)	អណ្តូងស្នប់	1
		អណ្តូងមានការថែរក្សាអនាម័យល្អ	2
		អណ្តូងគ្មានការថែរក្សាអនាម័យ	3
		ទន្លេ បឹង អូរ ព្រែក	4
		ទឹកភ្លៀង	5
		ប្រភពទឹកផ្សេងទៀត (បញ្ជាក់)........	6

56.	តើប្រភពថាមពលចំបងសំរាប់បំភ្លឺបានមកពីណា? (ចំលើយតែមួយ)	អគ្គិសនីរដ្ឋ	1
		អគ្គិសនីឯកជន	2
		អាគុយ	3
		ប្រេង	4
		ប្រភពផ្សេងទៀត (បញ្ជាក់)........	5
57.	តើប្រភពថាមពលអ្វីសំរាប់ចំអិនអាហាររបស់អ្នក? (ចំលើយច្រើន)	ដុតអុស	1
		ធ្យូង	2
		ហ្គាស	3
		ប្រេង	4
		(ប្រភពផ្សេងទៀត (បញ្ជាក់)........	5

		ដីលំនៅដ្ឋាន	ដីស្រែ/ចម្ការ	ដីផ្សេងទៀត
58.	**កម្មសិទ្ធដី** តើសព្វថ្ងៃអ្នកមានដី..........ដែរ ឬទេ?	1- បាទ/ចាស 0- ទេ	1- បាទ/ចាស 0- ទេ	1- បាទ/ចាស 0- ទេ
9.	តើជាមធ្យមពីផ្ទះអ្នកទៅដីទាំងនេះមានចំងាយប៉ុន្មាន Km?	....	..........Km ....Km ....Km ....Km	..........Km ....Km ....Km ....Km
0.	តើអ្នកកាន់កាប់ដីទាំងនេះប៉ុន្មានឆ្នាំហើយ?	....	....	....
1.	តើអ្នកមានដីប៉ុន្មានឡូត៍/កន្លែង?	....	....	....
2.	តើដីទាំងនេះមានទំហំប៉ុណ្ណា?	..........m2 ....m2 ....m2 ....m2	..........m2 ....m2 ....m2 ....m2	..........m2 ....m2 ....m2 ....m2

3.	តើអ្នកបានទទួលដីទាំងនេះដោយរបៀបណា? (ចម្លើយតែមួយ)	តាមរយៈក្រុមសាមគ្គីតាំងពីឆ្នាំ១៩៨០	1
		ការទន្ទ្រានយកដី	2
		ទិញពីគេ	3
		មរតកពីម្តាយឪពុក/សាច់ញាតិ	4
		តាមរយៈផ្សេងទៀត ______________	5
1.	តើបច្ចុប្បន្នដីទាំងអស់ភាគច្រើនមានបណ្ណ័កម្មសិទ្ធប្រភេទអ្វី? (ចម្លើយតែមួយ)	ប្លង់រឹងចេញដោយរដ្ឋាភិបាល	1
		មានបង្កាន់ដៃចេញពីអាជ្ញាធរមូលដ្ឋាន	2
		គ្រាន់តែមានការអនុញ្ញាតអោយស្នាក់នៅ	3

		គ្មានឯកសារអ្វីទាំងអស់	4
4.45.	តើភាគច្រើនដីរបស់អ្នកជាប្រភេទដីសំរាប់ធ្វើកសិកម្ម ឬ?	1- បាទ/ចាស	0- ទេ

4.46.	តើអ្នកធ្លាប់បានជួលដី ណាមួយអោយគេដែរឬទេក្នុងរយៈពេល12ខែកន្លងមកនេះ?	ដីលំនៅដ្ឋាន	ដីស្រែ/ចម្ការ	ដីផ្សេងទៀត
		1- បាទ/ចាស 0- ទេ	1- បាទ/ចាស 0- ទេ	1- បាទ/ចាស 0- ទេ
4.47.	បើធ្លាប់បានជួល តើដីនោះជួលសំរាប់ធ្វើអ្វី និងមានទំហំប៉ុណ្ណា?			
	1- សំរាប់រស់នៅ	..........m^2	..........m^2	.......m^2
	2- សំរាប់ធ្វើស្រែវស្សា	..........m^2	..........m^2	.......m^2
	3- សំរាប់ធ្វើស្រែប្រាំង	..........m^2	..........m^2	.......m^2
	4- សំរាប់ធ្វើចំការ	..........m^2	..........m^2	.......m^2
	5- ផ្សេងទៀត......................	..........m^2	..........m^2	.......m^2

4.48.	ទ្រព្យសម្បត្តិគ្រួសារ	ចំនួន	សរុបជាដុល្លា	កំណត់សំគាល់
	1. គោ			
	2. ក្របី			
	3. ជ្រូក			
	4. មាន់			
	5. ទា			
	6. ក្ងាន			
	7.			
	8.			
	9.			
	10. ម៉ាស៊ីនបូមទឹក			
	11. ម៉ាស៊ីនច្រូតស្រូវ			
	12. ម៉ាស៊ីនដេរ			
	13. ម៉ាស៊ីនភ្លើង			
	14. ម៉ាស៊ីនកិនស្រូវ			
	15. ម៉ាស៊ីនបោកស្រូវ			
	16. ម៉ាស៊ីនសំរាប់សាកអាគុយ			
	17. ម៉ាស៊ីនអារឈើ (ខ្នាតតូចchainsaw)			
	18. ម៉ាស៊ីនអារឈើ (ខ្នាតធំhug-saw)			
	19.			
	20.			

21.			
22. រទេះគោ			
23. កង់			
24. ម៉ូតូ			
25. យានយន្ត(រថយន្តដឹកទំនិញ/រថយន្តទេសចរណ៍)			
26. ទូកគ្មានម៉ាស៊ីន			
27. ទូកមានម៉ាស៊ីន			
28. រទេះសេះ			
29. នង្គ័ល			
30. រនាស់			
31.			
32.			
33.			
34. ទូរទស្សន៍			
35. វិទ្យុ/ម៉ាញេ/MP3/MP4			
36. CD/VCD/DVD player			
37. អាគុយ			
38.			
39.			
40.			

V. លទ្ធភាពដែលអាចទទួលបានពីធនធានធម្មជាតិ (រាប់បញ្ចូលទាំងព្រៃឈើ)

1.	តើអ្នកបានទទួលផលពីធនធានធម្មជាតិដែលមានក្នុងភូមិ/ក្រៅភូមិរបស់អ្នកដែរឬទេ?	1-. បាទ/ចាស	0-. ទេ
2.		តើប្រភពណាខ្លះដែរអ្នកទទួលបានផលពីធនធានធម្មជាតិ? *(ចម្លើយច្រើន)*	តើមានចំងាយប៉ុន្មានពីភូមិអ្នកទៅដល់កន្លែងទាំងនោះ?
3.	*បើ5.1 បាទ/ចាស*	1 ព្រៃស្តុក 2. ទន្លេ ជ្រោះ បឹង 3. តំបន់លិចទឹក 4. ដៃទន្លេ ដៃជ្រោះ ដៃបឹង 5. ប្រព័ន្ធទឹក ព្រែកតូច 6. ផ្សេងៗ(បញ្ជាក់)	...............km ....km ....km ....km ....km ....km

5.4.	តាមការគិតរបស់អ្នកតើធនធានធម្មជាតិមានការប្រែប្រួលកម្រិតណា បើធៀបកាលពី៥ឆ្នាំមុន?	កើនឡើង	ថយចុះ	គ្មានការផ្លាស់ប្តូរ	មិនដឹង
	1. ព្រៃស្តុក	1	1	1	1
	2. ទន្លេ អូរ បឹង	2	2	2	2
	3. ដីលិចទឹក	3	3	3	3
	4. ដៃទន្លេ ដៃអូរ មាត់បឹង	4	4	4	4
	5. ប្រព័ន្ធប្រឡាយទឹក ព្រែក	- 5	5	5	5
	6. ផ្សេងៗ(បញ្ជាក់)......................	6	6	6	6

5.5.	*ប្រសិនបើមានការប្រែប្រួលខ្លាំង* តើវាកើតឡើងដោយសារមូលហេតុអ្វី? (ចម្លើយមិនលើសពី ៣)	1. ការយកផលលើសកំណត់ 2. ការប្រែប្រួលបរិស្ថាន 3. កំណើនប្រជាជន 4. ការបំផ្លាញដោយសម្បទានិក 5. ការហាមឃាត់នូវការយកផលដោយសម្បទានិក 6. ការបំផ្លាញដោយសកម្មភាពអ្នកភូមិ 7. ការការពារព្រៃឈើ (តំបន់អភិរក្ស) 8. ផ្សេងៗ(បញ្ជាក់)...................................

5.6	តើអ្នកដឹងពីកន្លែងដែលមានធនធានធម្មជាតិដែលអ្នក/អ្នកភូមិធ្លាប់ទៅរកផលបានដោយសេរី តែឥឡូវត្រូវបានហាមឃាត់ដែរឬទេ?	1 បាទឬចាស	2 ទេ

5.7.	ប្រសិនបើកន្លែងខ្លះត្រូវបានហាមឃាត់ តើមានកន្លែងណាខ្លះ? *(ចម្លើយមានច្រើន)*	ព្រៃស្តុក	1
		ទន្លេ អូរ បឹង	2
		ដីលិចទឹក	3
		ដៃទន្លេ ដៃអូរ មាត់បឹង	4
		ប្រព័ន្ធប្រឡាយទឹក ព្រែកតូចៗ	5
		ផ្សេងៗ(បញ្ជាក់)........................	6

5.8.	ប្រសិនបើអ្នកត្រូវបានហាមឃាត់មិនអោយចូលទៅតំបន់នោះ តើវាប៉ះពាល់ដល់ជីវភាពរស់នៅរបស់អ្នកកំរិតណា?	គ្មានទាល់តែសោះ	1
		ប៉ះពាល់តិចតួច	2
		ប៉ះពាល់មធ្យម	3
		ប៉ះពាល់ខ្លាំង	4
		មិនដឹង	5

VI. *សកម្មភាព/ ប្រភពចំណូលក្នុងគ្រួសារ*

តើអ្វីជាប្រភពចំណូលចម្បងបច្ចុប្បន្នរបស់គ្រួសារអ្នកគឺជាអ្វី? *(សូមរៀបរាប់ពីមុខរបរចម្បង)*	សូមបញ្ជាក់ពីសកម្មភាពចំណូលចំបងទី ១ ___ ចំណូលមធ្យមប្រចាំខែ ______ ដុល្លា		
តើនរណាជាអ្នកសំខាន់ក្នុងការរកប្រាក់ចំណូលនៅក្នុងគ្រួសារអ្នក?	1 បុរស	2 ស្ត្រី	3 ទាំងពីរ
ប្រៀបធៀបប្រាក់ចំណូលឆ្នាំមុននឹងឆ្នាំនេះ:	1 កើនឡើង	2 ថយចុះ	3 ដដែល
តើប្រភពចំណូលទីពីរនាពេលបច្ចុប្បន្នរបស់គ្រួសារអ្នកគឺជាអ្វី? *(សូមរៀបរាប់ពីមុខរបរចម្បង)*	សូមបញ្ជាក់ពីសកម្មភាពប្រភពចំណូលទី ២ ______ ចំណូលមធ្យមប្រចាំខែ______ ដុល្លា		
តើនណាជាអ្នកសំខាន់ក្នុងការរកប្រាក់ចំណូលនៅក្នុងគ្រួសារអ្នក?	1 បុរស	2 ស្ត្រី	3 ទាំងពីរ
ប្រៀបធៀបប្រាក់ចំណូលឆ្នាំមុននឹងឆ្នាំនេះ:	1 កើនឡើង	2 ថយចុះ	3 ដដែល
តើប្រភពចំណូលទីបីនាពេលបច្ចុប្បន្នរបស់គ្រួសារអ្នកគឺជាអ្វី? *(សូមរៀបរាប់ពីមុខរបរចម្បង)*	សូមបញ្ជាក់ពីសកម្មភាពប្រភពចំណូលទី ៣ ចំណូលមធ្យមប្រចាំខែ______ដុល្លា		
តើអ្នកណាជាអ្នកសំខាន់ក្នុងការរកប្រាក់ចំណូលនៅក្នុងគ្រួសារអ្នក?	1 បុរស	2 ស្ត្រី	3 ទាំងពីរ
ប្រៀបធៀបប្រាក់ចំណូលឆ្នាំមុននឹងឆ្នាំនេះ:	1 កើនឡើង	2 ថយចុះ	3 ដដែល
តើមានសមាជិកណាម្នាក់ក្នុងគ្រួសារអ្នករកចំណូលពីការចូលព្រៃដែរ ឬទេ? *បើគ្មានរំលងទៅ V*	1 មាន		2 គ្មាន
ប្រសិនបើ410មាន តើផលដែលទទួលបានជាអ្វី? *(ចម្លើយមានច្រើន)*	1- ការកាប់ឈើ 4- ការច្រូតស្បូវ 7- ធ្យូង 9- ការប្រមាញ់	2-ដើមឈើសំរាប់ធ្វើឱសថបន្ទគ្រឹស្នា 5-ឬស្សី 8-ល្អី កន្ទេល 10-ជ័រ	3-ផ្តៅ/ វល្លិ 6-អុស 11- ផ្សេងៗ

VII.	ប្រាក់ចំណូលដែលរកបានពីផល-អនុផលព្រៃឈើ		
7.1.	តើសមាជិកគ្រួសារអ្នកបាននឹងកំពុងចូលរួមក្នុងការប្រមូលផល-អនុផលព្រៃឈើដែររឺទេ?	1 មែន	2 មិនមែន
7.2.	*ប្រសិនបើមាននរណាម្នាក់ក្នុងគ្រួសារអ្នកចូលទៅក្នុងព្រៃដើម្បីរកផលព្រៃឈើផ្សេងៗ* តើជារៀងរាល់ខែមួយនៃគ្រួសារអ្នកមានសមាជិកប៉ុន្មាននាក់ដែលចូលក្នុងព្រៃ ហើយម្តងៗរយៈពេលប៉ុន្មានថ្ងៃ?	ចំនួនមនុស្ស	ចំនួនថ្ងៃ
7.3.	*ប្រសិនបើមាន* តើអ្នកចំណាយអស់ប៉ុន្មានទៅលើរបស់របរដូចតទៅនេះក្នុងកំឡុងពេល12 ខែចុងក្រោយ?	1-ថ្លៃកម្មករ	……………ដុល្លា
		2-ថ្លៃកំរៃជើងសារ (*អ្នកថែទាំព្រៃឈើ ប៉ូលីស*)	……………ដុល្លា
		3-ថ្លៃធ្វើដំណើរ	……………ដុល្លា
		4-ថ្លៃសាំង	……………ដុល្លា
		5-ថ្លៃសម្ភារៈ (រណា)	……………ដុល្លា
		6-ថ្លៃទិញផលិតផលព្រៃឈើ	……………ដុល្លា
		7-ចំណាយទៅលើសម្បទានិក	……………ដុល្លា
		8-ចំណាយផ្សេងៗ	……………ដុល្លា
7.4.	តើអ្នករកចំណូលបាន ប៉ុន្មានពីព្រៃលើរយៈពេល១២ខែចុងក្រោយនេះ ?	……………………………ដុល្លា	
7.5.	តើមានប៉ុន្មានភាគរយដែលលក់?	……………………………%	
7.6.	តើមានប៉ុន្មានភាគរយសំរាប់ប្រើប្រាស់ក្នុងគ្រួសារ?(%)	……………… ……………%	
7.7.	តើមានប៉ុន្មានភាគរយចែកជាមួយនឹងឪពុកម្តាយ/សាច់ញាតិ?(%)	……………………………%	

VIII.	ផលិតផលកសិកម្មបែបគ្រួសារ		
8.1.	តើគ្រួសាររបស់អ្នកបានដាំដុះដំណាំដែររឺទេ កាលពីឆ្នាំមុន?	1.បាទ/ចាស	0.ទេ
8.2.	បើមានដាំដុះ តើប្រភេទដំណាំអ្វីខ្លះ? (ចំលើយច្រើន)	1. ស្រូវ 2. ពោត 3. សណ្តែក 4. ដំឡូង 5. ផ្សេងៗ......	

8.3.	តើអ្នកទទួលបានផល និងគិតជាការលក់ផលដំណាំទាំងនោះចំនួនប៉ុន្មានកាលពីឆ្នាំទៅ?	គីឡូ	ដុល្លា
	1. ស្រូវ		
	2. ពោត		
	3. សណ្ដែក		
	4. ដំឡូង		
	5. ផ្សេងៗ......		

IX. ប្រភពចំណូលផ្សេងៗទៀត(ក្នុងកំឡុងពេល12ខែចុងក្រោយ)

			ចំនួនដងដែលបានលក់	ចំណូលគិតជាដុល្លា
1.	ស្វាយ (ឡូ)	1.បាទ/ចាស 0.ទេ		
2.	ចេក (ស្និត)	1.បាទ/ចាស 0.ទេ		
3.	ខ្នុរ (ផ្លែ)	1.បាទ/ចាស 0.ទេ		
.	ដូង (ផ្លែ)	1.បាទ/ចាស 0.ទេ		
.	អំពៅ	1.បាទ/ចាស 0.ទេ		
.	....	1.បាទ/ចាស 0.ទេ		
.	....	1.បាទ/ចាស 0.ទេ		

X. ការលក់សត្វចិញ្ចឹម

			ចំនួនដងដែលបានលក់	ចំណូលគិតជាដុល្លា
1	គោ ក្របី (ក្បាល)	1.បាទ/ចាស 0.ទេ		
2	ជ្រូក (ក្បាល)	1.បាទ/ចាស 0.ទេ		
3	មាន់ ទា (ក្បាល)	1.បាទ/ចាស 0.ទេ		

10.4	ស៊ុត (គ្រាប់)	1.បាទ/ចាស 0.ទេ		
10.5	ផ្សេងៗ............	1.បាទ/ចាស 0.ទេ		

XI. ប្រាក់ចំណូល ពីការលក់កម្លាំងពលកម្ម

ក្នុងកំឡុងពេល ៩ខែចុងក្រោយ		ចំនួសមាជិកដែលទៅធ្វើជាកម្មករ	កំរៃប្រចាំថ្ងៃ	កំរៃប្រចាំខែ	ចំនួនខែដែលធ្វើការងារ
11.1.	ការងារកសិកម្ម				
11.2.	នេសាទ				
11.3.	ការងាររោងចក្រ				
11.4.	ការងារសំណង់				
11.5.	ការបំរើសេវាកម្ម				
11.6.	ផ្សេងៗ..				

XII. វិបត្តិដែលនាំអោយខ្វះខាតស្បៀងអាហារ និងបាត់បង់ចំណូលគ្រួសារ

12.1.	តើមានគោឬក្របីងាប់ ដែរឬទេ ក្នុងអំឡុងពេល ១២ខែកន្លងមកនេះ?	1 បាទ/ចាស	2 ទេ	
12.2.	តើមានគោឬក្របីត្រូវបានលួចដែរឬទេ ក្នុងអំឡុងពេល ១២ខែកន្លងមកនេះ?	1 បាទ/ចាស	2 ទេ	
12.3.	តើមានជ្រូកងាប់ ដែរឬទេ ក្នុងអំឡុងពេល ១២ខែកន្លងមកនេះ?	1 បាទ/ចាស	2 ទេ	
12.4.	តើមានជ្រូកត្រូវបានលួចដែរឬ ក្នុងអំឡុងពេល ១២ខែកន្លងមកនេះ?	1 បាទ/ចាស	2 ទេ	
12.5.	តើមាន មាន់/ទា/ក្ងាន ងាប់ ដែរឬទេ ក្នុងអំឡុងពេល ១២ខែកន្លងមកនេះ?	1 បាទ/ចាស	2 ទេ	
12.6.	តើមានមាន់/ទា/ក្ងានត្រូវបានលួចដែរឬទេ ក្នុងអំឡុងពេល ១២ខែកន្លងមកនេះ?	1 បាទ/ចាស	2 ទេ	
12.7.	តើមានសមាជិកណាម្នាក់ក្នុងគ្រួសារអ្នកបាត់បង់ការងាររកប្រាក់កំរៃដែរឬទេកាលពីឆ្នាំមុន?	1 បាទ/ចាស	2 ទេ	3 មិនដឹង
12.8.	បើមាន តើមូលហេតុអ្វី?	....		
12.9.	តើមានសមាជិកណាម្នាក់ក្នុងគ្រួសារអ្នកធ្លាក់ខ្លួនឈឺធ្ងន់ ឬត្រូវរបួសជាបេចាហេតុដែរឬទេក្នុងឆ្នាំនេះ?	1 បាទ/ចាស	2 ទេ	
12.10.	បើមាន តើមូលហេតុអ្វី?	....		

2.11	បើមាន តើជាញឹកញាប់ អ្នក ឬគ្រួសារអ្នកស្វែងរកការព្យាបាលនៅកន្លែងណា? (ចំលើយបាន៣)	1. ប៉ុស្តិ៍សុខភាព 2. មណ្ឌលសុខភាព 3. មន្ទីរពេទ្យរដ្ឋ 4. ពេទ្យឯកជនក្នុងភូមិ 5. ពេទ្យឯកជនក្នុងស្រុក/ខេត្ត 6. ពេទ្យបុរាណ 7. ផ្សេងៗ......	
2.12	តើមានសមាជិកណាម្នាក់ក្នុងគ្រួសារអ្នកទទួលមរណៈភាពដែរ ឬទេ ក្នុងឆ្នាំនេះ?	1 បាទ/ចាស	2 ទេ
2.13	តើមានសមាជិកណាម្នាក់ក្នុងគ្រួសារអ្នករៀបការក្នុងឆ្នាំនេះដែរ ឬទេ?	1 បាទ/ចាស	2 ទេ

XIII. **វិធីដើម្បីដោះស្រាយនូវវិបត្តិខាងលើ**

.1.	តើក្នុងឆ្នាំនេះអ្នកនិងគ្រួសារអ្នកធ្លាប់ខ្ចីលុយពីអ្នកចងការប្រាក់?	1 បាទ/ចាស	2 ទេ	
.2.	តើក្នុងឆ្នាំនេះអ្នកនិងគ្រួសារអ្នកធ្លាប់ខ្ចីលុយពីសាច់ញាតិ?	1 បាទ/ចាស	2 ទេ	
.3.	តើក្នុងឆ្នាំនេះអ្នកនិងគ្រួសារអ្នកមានថ្ងៃណាដែរ មិនបានបរិភោគអាហារ ព្រោះតែការដាច់អាហារដែរ ឬទេ?	1 បាទ/ចាស	2 ទេ	3 មិនដឹង

XIV. ស្ថានភាពនៃការគ្រប់គ្រងព្រៃឈើក្នុងតំបន់

.1.	តើអ្នកមានដឹងថាតំបន់នេះមានព្រៃសម្បទានដែរ ឬទេ?	1 បាទ/ចាស	2 ទេ		
2.	*ប្រសិនបើមាន*តើអ្នកមានដឹងថាតំបន់សម្បទានទាំងនេះមានដែនកំណត់ជាក់លាក់ដែរ ឬទេ?	1 បាទ/ចាស	2 ទេ	3 មិនដឹង	
3.	តើក្នុងតំបន់សម្បទាននេះមានអ្នកយាមដែរឬទេ?	1 មាន(គ្មានអាវុធ)	2 មាន(មានអាវុធ)	3 គ្មាន	4 មិនដឹង
4.	*ចាប់តាំងពីមានព្រៃសម្បទាននៅទីនេះ:* ប្រៀបធៀបនឹងពីមុនតើអ្នកចូលទៅក្នុងព្រៃញឹកញាប់កម្រិតណាដើម្បីរកផល-អនុផល ព្រៃឈើ?	1 ញឹកញាប់ជាងមុន	2 មិនសូវញឹកញាប់ទេ	3 ដូចពីមុន	4 មិនដឹង
5.	ចាប់តាំងពីព្រៃសម្បទានត្រូវបានបង្កើតឡើងនៅទីនេះ តើម្ចាស់ព្រៃសម្បទានមានហាមឃាត់ប្រជាជនមិនអោយចូលទៅក្នុងព្រៃសម្បទាននោះដែរឬទេ?	1 មាន	2 គ្មាន	3 មិនដឹង	

14.6.	*ប្រសិនបើនៅតែមានការអនុញ្ញាតអោយចូល* តើប្រជាជនអាចប្រមូលផលិតផលអ្វីខ្លះ?	1. គល់ឈើធំៗ 2. ជ័រ 3. អុស ឈើសំរាប់ធ្វើធ្យូង 4. សត្វព្រៃ 5. វល្លិ និង ផ្តៅ 6. ស្បូវ 7. ផ្សេងៗ		
14.7.	ប្រសិនបើនៅតែអនុញ្ញាតអោយចូលតើប្រជាជនត្រូវបង់ប្រាក់ដែរ ឬទេ?	1 បាទ/ចាស	2 ទេ	3 មិនដឹង
14.8.	តើតំបន់នេះមានសហគមន៍ព្រៃឈើដែរឬទេ?	1 មាន		2 គ្មាន
14.9.	ប្រសិនបើមាន តើឈ្មោះអ្វី?	....		
14.10.	តើសហគមន៍ ព្រៃឈើនេះមានមុខងារធ្វើអ្វីខ្លះ?	1 .... 2 .... 3		
14.11.	តើអ្នកភូមិមានទទួលបានផលប្រយោជន៍ពីសហគមន៍នេះដែរឬទេ?	1 បាទ/ចាស	2 ទេ	3 មិនដឹង
14.12.	ប្រសិនបើមានសហគមន៍ព្រៃឈើ តើអ្នក ឬនរណាម្នាក់ក្នុងគ្រួសារជាសមាជិកដែរឬទេ?	1 បាទ/ចាស		2 ទេ

XV.	ទិន្នន័យសុខភាព និងសេវាសង្គម	
15.1.	តើអ្នកអាចពិពណ៌នាយ៉ាងដូចម្តេចចំពោះស្ថានភាពសុខភាពនៃសមាជិកគ្រួសាររបស់អ្នក?	1. សុខភាពធម្មតា 2. កម្រឈឺណាស់ 3. តែងតែឈឺ (សុខភាពខ្សោយ) 4. ឈឺរហូត(កាលពី៥ឆ្នាំមុនឬច្រើនជាង) 5. ផ្សេងៗ (បញ្ជាក់):________
15.2.	ប្រភេទជម្ងឺដែលសមាជិកគ្រួសារអ្នក កើតកាលពី ៥ឆ្នាំមុន	1. ជម្ងឺបេះដូង (លើសឈាម, ដាច់សសៃឈាមខួរក្បាល, ឈឺទ្រូង ។ល។) 2. ទឹកនោមផ្អែម(ឡើងជាតិស្ករខ្ពស់) 3. ពោះវៀន(ដំបៅក្រពះ, ឈឺក្រពះ 4. ភាគរូស, គ្រុនពោះវៀន 5. រលាកផ្លូវដង្ហើមដូចជាជម្ងឺហឺត,គ្រុន, ផ្តាសាយ, គ្រុនចាញ់ ។ល។

6. របេង ហើយ រលាក/ជម្ងឺសួត
7. គ្រុនចាញ់
8. មហារីក
9. រោគសន្លាក់ឆ្អឹង (ឈឺឆ្អឹង. ភាពស)
10. ជម្ងឺដែលទាក់ទង ភ្នែក/ត្រចៀក ច្រមុះ និង បំពង់ក
11. (ផ្សេងៗ (បញ្ជាក់):______

...3. តើមានចម្ងាយប៉ុន្មានពីផ្ទះរបស់អ្នកទៅគ្លីនិក/មន្ទីរពេទ្យ? សូមគូសខាងក្រោម		15.4. តើអ្នកទៅមណ្ឌលសុខភាព/មន្ទីរពេទ្យដោយមធ្យោបាយអ្វី? ចំណាយរយៈពេលប៉ុន្មានម៉ោង? សូមគូសខាងក្រោម		15.5. តើសេវាសុខភាព/សេវាព្យាបាលណាដែលអ្នក/សមាជិកគ្រួសារអ្នកបានទទួល?
...nic/គ្លីនិក	Hospital/មន្ទីរពេទ្យ	Means of Transportation មធ្យោបាយធ្វើដំណើរ	Time spent/ចំណាយពេល (Minutes or Hr.)	
Below 20 ms. 0.5 km	☐ 1. 1-3km	☐ 1. By foot/ walking ដោយថ្មើរជើង	☐ 1. 15 minutes or below	☐ 1. ត្រួតពិនិត្យសុខភាព
1-2 km	☐ 2. 4-6km	☐ 2. Bicycle ដោយកង់	☐ 2. 16-30 mins	☐ 2. ព្យាបាល/បានទទួលថ្នាំពេទ្យ
3-4 km	☐ 3. 7-9 km	☐ 3. Motorbike ដោយម៉ូតូ	☐ 3. 31 – 45 Minute	☐ 3. ការចាក់ថ្នាំបង្ការរោគឆ្លង
5-6 km	☐ 4. 10-12 km	☐ 4. Car/Taxi ដោយរថយន្ត/តាក់ស៊ី	☐ 4. 45mins To 1 hour	☐ 4. ការវះកាត់
6 km or more	☐ 5. 13-15 km	☐ 5. Other (specify) ផ្សេងៗ(បញ្ជាក់) ____	☐ 5. More than 1 hour	☐ 5. ផ្សេងៗ(បញ្ជាក់):________
[illegible]	☐ 6. 16 km or more			
តើសេវាទាំងនោះគេផ្តល់ឲ្យដោយមិនបង់ប្រាក់មែនទេ?				☐ 6. Yes/បាទ/ចាស ☐ 7. No/ទេ

អរគុណដែលបានសហការ

កម្រងសំណួរក្នុងការប្រជុំជាក្រុមសម្រាប់ការធ្វើអង្កេតវាយតំលៃហេតុប៉ះពាល់សង្គម

កាលបរិច្ឆេទ: ទីតាំង:

ក្រុម:

១- ពត៌មានអំពីអ្នកចូលរួម:

លរ	ឈ្មោះ	អាយុ	ភេទ	មុខរបរ
១				
២				
៣				
៤				
៥				
៦				
៧				
៨				
៩				
១០				
១១				
១២				

២- ពត៌មានពាក់ព័ន្ធនឹងសង្គម សេដ្ឋកិច្ចៈ

១. អ្នកចូលរួមដែលចេះអាន និងចេះសរសេរមានប៉ុន្មាននាក់?	
២. ប្រភពចំណូលសំខាន់ៗ	
៣. ប៉ុន្មានភាគរយនៃប្រាក់ចំណូលគ្រួសារសរុប?	
៤. ប្រាក់ចំណូលបានពីធនធានធម្មជាតិមានអ្វីខ្លះ? ហើយមានប៉ុន្មានភាគរយនៃប្រាក់ចំណូលគ្រួសារសរុប?	
៥. អ្នកណាជាអ្នករកចំណូលប្រចាំគ្រួសារ (ប្រុស ឬស្រី?)	
៦. ចម្ងាយផ្លូវទៅដល់កន្លែងប្រកបមុខរបរ	
៧. ចម្ងាយផ្លូវទៅកាន់ធនធានធម្មជាតិ	
៨. មធ្យោបាយធ្វើដំណើរដែលប្រើប្រាស់ក្នុងភូមិ ទាំងក្នុង	

សកម្មភាពរកប្រាក់ចំណូល

៩. បំរែបំរួលនៃជីវភាពរស់នៅ ក្នុងរយៈប្រាំឆ្នាំចុងក្រោយ (ប្រសើរឡើង ឬអន់ចុះ)?

១០.មានការផ្លាស់ប្តូរ[illegible]ដែរឬទេក្នុងរយៈ៥ឆ្នាំចុងក្រោយនេះ?

១១.អ្នកចូលរួមប្រជុំប៉ុន្មាននាក់ជាអ្នកក្រ?

១២.ប៉ាន់ស្មានថាតើនៅក្នុងភូមិអ្នកមានគ្រួសារក្រីក្រប៉ុន្មាន?

១៣.ភាពក្រីក្រ និងនិន្នាការ ៥ឆ្នាំកន្លងមកនេះ

៣.ភាពប្រាស្រ័យទៅនឹងដីធ្លី និងធនធានធម្មជាតិ:

ការប្រើប្រាស់ និងសិទ្ធិកាន់កាប់ដីធ្លី(ដីលំនៅដ្ឋាន,ដីស្រែចំការ និងផ្សេងៗ)

លេខកូដ	ដីលំនៅដ្ឋាន		ដីស្រែចំការ/ដីកសិកម្ម		ដីផ្សេងៗ	
	ទំហំ(ហិកតា)	កម្មសិទ្ធដី	ទំហំ(ហិកតា)	កម្មសិទ្ធដី	ទំហំ(ហិកតា)	កម្មសិទ្ធដី

១៤. តើជីវភាពរស់នៅរបស់អ្នកសព្វថ្ងៃពឹងផ្អែកលើដីស្រែចំការដែលអ្នកកាន់កាប់មានកំរិតប៉ុណ្ណា? ពិភាក្សាអំពីភាពចាំបាច់ ។. ច្រើន ឬតិច ដោយពឹងផ្អែកលើដីស្រែចំការ។

១៥. តើមានធនធានធម្មជាតិណាខ្លះនៅក្បែរអ្នកដែលអ្នកអាចប្រាស្រ័យបានសំរាប់ជីវភាពរស់នៅ?

ប្រសិនបើមាន តើអ្នកអាចប្រើប្រាស់ធនធានធម្មជាតិនេះបានយូរប៉ុនណា? តើអ្នក[illegible]?	
១៦ ពិភាក្សាបញ្ហានៃការប្រើប្រាស់ធនធានធម្មជាតិ [illegible] បរិមាណនៃការប្រមូលបានពីមុនមក [illegible] ការទប់ស្កាត់មិនឲ្យគេកាប់ [illegible]	
១៧. តើជីវភាពរស់នៅរបស់អ្នកសព្វថ្ងៃនឹង[illegible]ធនធានធម្មជាតិទាំងនោះមានកំរិតប៉ុនណា? ពិភាក្សាអំពីភាពចាំបាច់ 2. ច្រើន ឬតិច ដោយពឹងផ្អែកលើធនធានធម្មជាតិទាំងនោះ។	
១៨. តើអ្នកគិតយ៉ាងដូចម្ដេចអំពីសុវត្ថិភាពដីធ្លីដែលអ្នកកំពុងកាន់កាប់? តើអ្នកគិតថាមានសុវត្ថិភាពជាង ឬគ្មានសុវត្ថិភាពជាងពីមុន និងទៅអនាគត?	
១៩. តើអ្នកគិតយ៉ាងដូចម្ដេចអំពីស្ថេរភាពនៃលទ្ធភាពរកធនធានធម្មជាតិ? តើអ្នកគិតថាមានសុវត្ថិភាពជាង ឬ គ្មានសុវត្ថិភាពជាងពីមុន និងទៅអនាគត?	

៤. ទំនៀមទំលាប់ ប្រពៃណី និងវប្បធម៌:

២០. ភូមិ ឬសហគមន៍នេះកកើតបានប៉ុន្មានឆ្នាំហើយ? អ្នកណាជាអ្នកដឹកនាំ? តើគាត់តែងតាំងដោយប្រជាជន ឬដោយសារការចាត់តាំងតាមក្រុមខ្សែនយោបាយ?	
២១. តើសហគមន៍របស់អ្នកមានប្រជាជនប៉ុន្មានតាមជាតិ:	ខ្មែរ: ចាម: វៀតណាម: ជនជាតិភាគតិច:
២២. តើក្រុមប្រជាជនទាំងនេះរស់នៅជាមួយ ឬនៅដោយឡែកពីប្រជាជនខ្មែរ?	
២៣. តើអ្នកដឹកនាំសហគមន៍របស់អ្នកផ្សេងពីមេភូមិឬ?	
២៤. ប្រសិនបើមែន តើគាត់ត្រូវបានចាត់តាំងយ៉ាងដូចម្ដេច? ដោយនរណា អ្នកភូមិ ឬអ្នកដទៃ?	

៥. លទ្ធភាពទទួលសេវាសាធារណៈ

២៥. តើនៅក្នុងភូមិរបស់អ្នក [illegible] សាលាបឋមសិក្សា អនុវិទ្យាល័យ [illegible] ថ្នាក់ទីប៉ុន្មានខ្លះ?	
២៦. ចំងាយទៅកាន់សាលា [illegible]?	[illegible] ដល់សាលាបឋមសិក្សា [illegible] ដល់អនុវិទ្យាល័យ [illegible] ដល់វិទ្យាល័យ
២៧. តើមានមណ្ឌលសុខភាព មន្ទីរពេទ្យ ឬគ្លីនិកឯកជននៅទីនេះទេ?	
២៨. ការកើតមានជំងឺផ្សេងៗក្នុងសហគមន៍:ជំងឺសាមញ្ញបំផុតអ្វីខ្លះដែលសហគមន៍ប្រឈមមុខ? មានការស្វែងរកមូលហេតុនៃជំងឺឬការថែទាំសុខភាពឬទេ?	
២៩. ប្រភពទឹកស្អាតតាមរដូវនីមួយៗ? ការប្រើប្រាស់ទូទៅយ៉ាងដូចម្តេច?	
៣០. ប្រភពថាមពល សំរាប់បំភ្លឺ ចំអិនមានអ្វីខ្លះ?មានអគ្គីសនីឬទេ?	
៣១. ចំនួនគ្រួសារដែលមានបង្គន់អនាម័យនៅផ្ទះ (ប៉ុន្មានភាគរយ)	

៦. បញ្ហាចំណាកស្រុក:

(ពិភាក្សាខ្លីថា តើសំខាន់ដែរឬទេ ហើយមានសក្តានុពលដែរឬទេ ចំពោះគ្រួសារក្រីក្រដែលត្រូវនាំគ្រួសារទាំងមូលផ្លាស់ទីដើម្បីរកការងារ?បើមាន វាកើតឡើងយ៉ាងដូចម្តេច?

៧. បញ្ហា Gender

៨. អំពើហិង្សាក្នុងគ្រួសារ

៩. បញ្ហា [illegible]

១០. ការយល់ដឹងអំពីហេតុប៉ះពាល់បណ្តាលមកពីសម្បទានដីៈ ច្រើន ឬតិច

១១. ប្រសិនបើយល់ដឹងច្រើន តើត្រូវកាត់បន្ថយហេតុប៉ះពាល់ទាំងនោះយ៉ាងដូចម្តេច?

១២. អ្នកភូមិប្រហែលប៉ុន្មានភាគរយទទួលយកការធ្វើសម្បទានដីនេះ ហើយប៉ុន្មានភាគរយមិនព្រមទទួលយក?

៤-១ លិខិតបទដ្ឋានច្បាប់របស់ដីសម្បទាន(ផែនការមេ)

កិច្ចសន្យា

ស្តីពី

ការវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី
និងសាងសង់រោងចក្រកែច្នៃ

រវាង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)

AGREEMENT

For

THE INVESMENT OF PLANTATION DEVELOPMENT
FOR RUBBER, CASSAVA, CASHEWNUT AND
PROCESSING FACTORY

Between

The Ministry of Agriculture, Forestry and Fisheries

And

DAU TU SAIGON-BINH PHUOC (SBK) Co, Ltd

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យា

ស្តីពី

ការវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងសាងសង់រោងចក្រកែច្នៃ

រវាង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

ក្រុមហ៊ុន ដូនីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)

<u>កិច្ចសន្យានេះធ្វើឡើងរវាង</u> :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តំណាងដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានអាស័យដ្ឋានលេខៈ ២០០ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១៧ ៣២០ មានគណនីលេខ : .... នៅធនាគារជាតិ នៃកម្ពុជាហៅថា ភាគី "ក" ។

ជាមួយនឹង

ក្រុមហ៊ុន ដូនីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) មានស្នាក់ការនៅផ្ទះលេខ ៥២ មហាវិថីព្រះនរោត្តម សង្កាត់ ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ៣៥៥ ៤២២ ហ្វាក់ លេខ ០២៣ ២២២ ៥៧៥ ដែលតំណាងដោយលោក ដាង ថាញ់ តាំ (DANG TANNH TAM) ជនជាតិវៀតណាម ឋានៈ អភិបាលក្រុមហ៊ុន មានគណនីលេខ ០១០-០២-៥៥-០២៧២៥-១ នៅធនាគារ វឌ្ឍនៈ ហៅថា ភាគី "ខ" ។

យោង : -ច្បាប់វិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា និង ច្បាប់វិសោធនកម្មនៃច្បាប់វិនិយោគនៃ ព្រះរាជាណាចក្រ កម្ពុជា

-ច្បាប់ភូមិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-តាមខ្លឹមសារលិខិតជូនដំណឹងលេខ ៣៧៧ សជណ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ [illegible] ទីស្តីការគណៈរដ្ឋមន្ត្រី ។

-លិខិតសិទ្ធិប្រទានលេខ ៣២ សប្រទ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ [illegible] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ មានដូចខាងក្រោមនេះ :

ប្រការ១ ៖ កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួន ប្រាំមួយពាន់បួនរយសាមសិបប្រាំមួយ (៦.៤៣៦) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ ជូនទៅភាគី "ខ" កាន់កាប់ [illegible] ដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងសាងសង់រោងចក្រកែច្នៃ ។ ទំហំផ្ទៃដីនេះបានបញ្ជាក់កាន់តែច្បាស់ក្នុងគំនូសផែនទីចំណុចទីតាំង ដែលបានបញ្ជាក់ ពីអាជ្ញាធរខេត្ត និងជំនាញមូលដ្ឋាន ដែលភ្ជាប់មកជាមួយជាឧបសម្ព័ន្ធនៃកិច្ចសន្យានេះ ដែលចាប់ពីពេលនេះតទៅ ហៅថា "ទីតាំង" និងមានកូអរដោណេដូចខាងក្រោម ៖

X : ៦៣៨០០០	Y : ១៣៧២០០៧
X : ៦៤២០០០	Y : ១៣៧០៩០០
X : ៦៤៤០៤៨	Y : ១៣៧៤០២២
X : ៦៤២៩៥០	Y : ១៣៨០៦៩២
X : ៦៤៣០០៧	Y : ១៣៧៩៨០០
X : ៦៣៩៥៩០	Y : ១៣៧១៨៤១
X : ៦៤៣៨៦៤	Y : ១៣៧៣៨០៤
X : ៦៣៨៥០០	Y : ១៣៨១៨០០
X : ៦៤៥៦០២	Y : ១៣៨០៦២០

យោងតាមកំណត់ហេតុចុះពិនិត្យសិក្សាវាយតម្លៃសំណើសុំដីសម្បទាន របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (វេអេសប៊ី ខេ) ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ (ដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ) ខាងលើនេះមាន ៖

១.១ ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់គឺ ចំណែកដីមិនពាក់ព័ន្ធនឹងដីពលរដ្ឋកាន់កាប់ស្របច្បាប់ និងដីដែលត្រូវរក្សាទុកជាលក្ខណៈធម្មជាតិ ដូចក្នុងចំណុច ១.២ និង ចំណុច ១.៣ នៃប្រការ ១ នេះ ។

១.២ ដីរបស់ពលរដ្ឋកាន់កាប់ដោយស្របច្បាប់ និងដីរបស់ប្រជាពលរដ្ឋកំពុងប្រកបរបរអាជីវកម្មកសិកម្មគ្រួសារ ត្រូវកាត់ចេញ ឬ ក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយប្រជាពលរដ្ឋដោយមានការយល់ព្រមទាំងសងខាង ។ ក្នុងករណីមានការរំលោភកាន់កាប់ដីសម្បទាននេះដោយខុសច្បាប់ ភាគី "ខ" មានសិទ្ធិប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច ។

១.៣ តំបន់បេតិកភណ្ឌវប្បធម៌ជាតិ ដីភ្នំ ដីអាងទឹក ដីព្រៃឈើដែលត្រូវការពារ ដីព្រៃជាលក្ខណៈប្រពៃណី និងតំបន់ការពារធម្មជាតិផ្សេងៗទៀត ។ល។ ត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ ។

១.៤ ចំនួនផ្ទៃដីដែលមានចែងក្នុងចំនុច ១.១ , ១.២ , ១.៣ ភាគី "ក" និង ភាគី "ខ" ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចសិក្សាស្រាវជ្រាវអង្កេតនិង កំណត់ទីតាំងផ្ទៃដីពាក់ព័ន្ធអោយបានចប់សព្វគ្រប់ក្នុងរយៈពេលបី (០៣) ខែ បន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខា ហើយត្រូវកាត់ចេញ ឬ មួយសម្របសម្រួលផ្ទៃដីពាក់ព័ន្ធទាំងអស់ ។ ក្រោយពីបានសិក្សាអង្កេតបានច្បាស់លាស់រួចហើយ ចំណែកនៃដីដែលក្រុមហ៊ុនអាចធ្វើអាជីវកម្ម[illegible]១.១ ភាគី "ខ"

2

ត្រូវស្នើសុំចុះបញ្ជីស្របតាមសារាចរណែនាំ លេខ ០៥ សរណន ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។ រាល់ការចំណាយនៃការចុះអង្កេតកំណត់ទីតាំង និងសម្របសម្រួលសងថ្លៃដីពាក់ព័ន្ធជាបន្ទុក របស់ភាគី " ខ " ។

ប្រការ២ : អំពីរយៈពេល

២.១ កិច្ចសន្យានេះមានរយៈពេលចិតសិប (៧០)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ សិទ្ធិនៃការកាន់កាប់ដីសម្បទាននឹងត្រូវប្រគល់ជូនបន្ទាប់ពីកិច្ចសន្យានេះចូលជាធរមានទៅតាមច្បាប់ជាធរមាន ។ សេចក្ដីជូនដំណឹង បញ្ចប់កិច្ចសន្យាត្រូវផ្ដល់ដំណឹងជាមុនចំនួនមួយ (០១) ឆ្នាំ ឬ នៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យា ។

២.២ ភាគី "ខ" មានសិទ្ធិសុំជួលបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេលចិតសិប (៧០)ឆ្នាំ។ រយៈពេលមួយ (០១) ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី " ខ " អាចសុំធ្វើវិនិយោគបន្តទៅទៀតហើយការបន្តអាចធ្វើឡើងទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាត ពីរាជរដ្ឋាភិបាលកម្ពុជាតាមសំណើររបស់ភាគី " ក " ដោយយោងទៅតាមការអនុវត្តន៍កន្លងមករបស់ភាគី " ខ " និងដោយ មានការពិភាក្សាឯកភាពពីភាគី " ក " អំពីលក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី ។

ប្រការ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និងកម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី " ខ " គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ច និងផែនការមេដែលក្រុមហ៊ុនត្រូវធ្វើដូចចំណុច ៧.៣ នៃមាត្រា ៧ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

៣.១ គោលដៅផលិតកម្ម-អាជីវកម្ម :

៣.១.១ ផលិតកម្មចំបង : ដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី

៣.១.២ ផលិតកម្មបន្ទាប់បន្សំ : ដំណាំកសិកម្មផ្សេងៗទៀត

៣.១.៣ ការសាងសង់ : សាងសង់រោងចក្រកែច្នៃ

៣.២ កម្មវិធីប្រើប្រាស់ទីតាំង : ភាគី "ខ" ត្រូវប្រើប្រាស់ក្នុងរយៈពេលបួន (០៤)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះអោយអស់ផ្ទៃដីដែលបានរៀបរាប់ក្នុងចំណុច ១.១ នៃប្រការ១ និង ដីដែលពាក់ព័ន្ធនឹងពលរដ្ឋហើយ ភាគី " ខ " បានសម្របសម្រួលដោះដូរ ឬសងទៅពលរដ្ឋដែលកាន់កាប់នោះរួចរាល់ហើយតាមផែនការឆ្នាំដូចខាងក្រោម :

ឆ្នាំទី១ : ១.០០០ (មួយពាន់) ហិកតា

ឆ្នាំទី២ : ២.០០០ (ពីរពាន់) ហិកតា

ឆ្នាំទី៣ : ២.០០០ (ពីរពាន់) ហិកតា

ឆ្នាំទី៤ : ១.៤៣៦ (មួយពាន់បួនរយសាមសិបប្រាំមួយ) ហិកតា

ប្រការ៤ : ប្រាក់កក់ និង ថ្លៃឈ្នួល

៤.១ ប្រាក់កក់: ភាគី " ខ " ត្រូវបង់ប្រាក់កក់ចំនួនស្មើ ១ USD (មួយដុល្លារអាមេរិក) [illegible] ហិកតា លើផ្ទៃដី [illegible] ដូចមានក្នុងប្រការ ១ សម្រាប់ធានាការអនុវត្តន៍កិច្ចសន្យានេះ ។ [illegible]

បី (០៣) ខែ ក្រោយពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា ។ ប្រាក់កក់នេះត្រូវបង្វិលសងវិញនៅពេលដែលភាគី " ខ " អនុវត្តការងារជុះចប់តាមគម្រោងក្នុងប្រការ ៣ ចំណុច ៣.២ ។

៤.២ ភាគី " ខ " ត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំតាមអត្រាថ្លៃឈ្នួលដីសម្បទានតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា ឬស្ថាប័នមានសមត្ថកិច្ច ។ប្រាក់ឈ្នួលត្រូវបង់ជាប្រចាំចូលថវិការដ្ឋតាមរយៈគណនីរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទឱ្យបានមុនថ្ងៃទី ៣១ ខែ មករា នៃឆ្នាំនីមួយៗ ។

៤.៣ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលតាមការកំណត់ដូចមានចែងក្នុងប្រការ ៤.២ ភាគី " ខ " ត្រូវទទួលពិន័យចំនួន ២ % (ពីរភាគរយ) ក្នុងមួយខែលើទឹកប្រាក់ឈ្នួលប្រចាំឆ្នាំនីមួយៗតាមចំនួនខែដែលយឺតយ៉ាវ ។

៤.៤ ភាគី " ខ " ត្រូវមានកាតព្វកិច្ចបង់ពន្ធផ្សេងៗ ទៀតជូនរដ្ឋតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមាន ។

ប្រការ៥ : ការផ្ទេរ ការជួលបន្ត ឬ ការលក់កិច្ចសន្យា

៥.១ ភាគី " ខ " អាចផ្ទេរទៅអោយឧត្តរាធិការីរបស់ខ្លួនបាន ។ ដែលហៅថាឧត្តរាធិការីជនស្របច្បាប់គឺជាបុគ្គលទាំងឡាយណាដែលភាគី " ខ " ប្រគល់ឱ្យស្នងកេរមរតករបស់ខ្លួននៅចំពោះមុខច្បាប់ឬបុគ្គលដែលទទួលស្គាល់ជាញាតិពន្ធ ។ ការប្រកាសជូនដំណឹងស្តីពីការផ្ទេរឬសម្រេចលើណាមួយទៅឱ្យឧត្តរាធិការីជនត្រូវជូនដំណឹងមកភាគី " ក " យ៉ាង តិច ០៦ ខែ មុនពេលចាប់ផ្តើមអនុវត្ត ។

៥.២ ភាគី " ខ " ក្រោមសិទ្ធិទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់និងកិច្ចសន្យានេះអាចសហការជាមួយក្រុមហ៊ុនដៃគូរបស់ខ្លួនបានដើម្បីអភិវឌ្ឍន៍ផលិតកម្ម-អាជីវកម្ម ដែលស្ថិតនៅក្នុងក្របខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យានេះ ។

៥.៣ ក្នុងករណី ភាគី " ខ " ជួលបន្ត ឬផ្ទេរកិច្ចសន្យានេះ ភាគី " ខ " ត្រូវអនុវត្តតាមច្បាប់វិនិយោគ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងមានការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមសំណើរបស់ភាគី " ក " ។

៥.៤ ដើម្បីរកទុនពីធនាគារក្នុង និងក្រៅប្រទេសមកពង្រីកការវិនិយោគទុនបន្ថែម ភាគី " ខ " មានសិទ្ធិយកដំណាំ និងទ្រព្យសម្បត្តិដែលបានចំណាយទុនវិនិយោគកន្លងមក នៅលើដីសម្បទាននោះសំរាប់យកទៅធានាបំណុល ។

ប្រការ៦ : សិទ្ធិ និង កាតព្វកិច្ចរបស់ភាគី " ក "

ភាគី " ក " មានសិទ្ធិ និង កាតព្វកិច្ចដូចខាងក្រោម:

៦.១ ជួយអន្តរាគមន៍ទៅស្ថាប័នដែលពាក់ព័ន្ធ ដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយដែលមានអ្នកប្រព្រឹត្តបទល្មើស រំលោភលើសិទ្ធិរបស់ភាគី " ខ " ក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍កិច្ចសន្យា និងការប្រើប្រាស់ទីតាំង ឬ រឹបអូសយកផ្ទៃណាមួយនៃទីតាំង ។

៦.២ ពេលដំណើរការគម្រោងវិនិយោគក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន " ក្នុងករណីមានទំនាស់ដីធ្លីវិនិយោគជាមួយប្រជាពលរដ្ឋ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិបង្អាក់ដីសម្បទាននេះទុកដើម្បីដោះស្រាយ និង ការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបើមានទំនាស់ដីធ្លីរវាងអ្នកវិនិយោគ និង ប្រជាពលរដ្ឋ ត្រូវផ្តល់អាទិភាពដោះស្រាយជូនប្រជាពលរដ្ឋ " ។

៦.៣ តាមដានត្រួតពិនិត្យលើ :

ការអនុវត្តកិច្ចសន្យារបស់ភាគី " ខ "

- ផលប៉ះពាល់លើបរិស្ថាន

- ការងារបច្ចេកទេស និង កម្មវិធីផលិតកម្ម-អាជីវកម្ម របស់ភាគី " ខ " ។

ប្រការ៧ : សិទ្ធិ និង ភារកិច្ចរបស់ភាគី "ខ"

ភាគី " ខ " មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម ៖

៧.១ បង់ប្រាក់កក់និងថ្លៃឈ្នួលត្រឹមត្រូវតាមប្រការ ៤ នៃកិច្ចសន្យានេះរហូតដល់ពេលចប់អាណត្តិ កិច្ចសន្យា ។

៧.២ ទទួលបន្ទុកចំណាយលើការអង្កេតសិក្សា និងចំណាយសម្របសម្រួលដោះដូរលើដីពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ ១ នៃចំណុច ១.៤ ។

៧.៣ ត្រូវធ្វើផែនការគ្រប់គ្រងនិងអភិវឌ្ឍន៍ទីតាំងជូនភាគី " ក " អោយបានយ៉ាងយឺត ០៦ខែ ក្រោយពីថ្ងៃចុះកិច្ចសន្យា។ ផែនការគ្រប់គ្រងនេះត្រូវមានផែនការមេនៃការអភិវឌ្ឍន៍យុទ្ធសាស្ត្រ កម្មវិធីការប្រើប្រាស់ទីតាំង ការប្រើប្រាស់បច្ចេកទេសផ្សេងៗ និងតុល្យភាពនៃផែនការសេដ្ឋកិច្ចហិរញ្ញវត្ថុក្នុងកិច្ចដំណើរការអភិវឌ្ឍន៍រយៈពេលវែង (រយៈពេលផ្តើមដំណើរការរហូតការប្រើប្រាស់អស់ដីទីតាំង និងរយៈពេលបន្ត) ។ ទន្ទឹមនេះ ត្រូវរៀបចំផែនការប្រចាំឆ្នាំនីមួយៗអោយបានច្បាស់លាស់សម្រាប់អនុវត្តការងារវិនិយោគប្រចាំឆ្នាំ ។ ភាគី " ខ " អាចចុះដំណើរការការងារបាន លុះត្រាតែមានការយល់ព្រមលើឯកសារផែនការគ្រប់គ្រង និងផែនការប្រចាំឆ្នាំអនុវត្ត ដោយភាគី " ក " ជាមុនសិន ។

៧.៤ ត្រូវប្រើប្រាស់កម្លាំងពលកម្មក្នុងស្រុកជាចាំបាច់ ក្នុងករណីគ្មានអ្នកឯកទេសខ្មែរក្នុងស្រុក ក្រុមហ៊ុនអាចរើសអ្នកឯកទេសបរទេស ដើម្បីជួយណែនាំបង្ហាត់បង្ហាញអំពីការងារ បច្ចេកទេសអាជីវកម្មផលិតកម្មតាមសេចក្តីត្រូវការចាំបាច់របស់ខ្លួន ដោយគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

៧.៥ យកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាព និងការអប់រំដល់បុគ្គលិក កម្មករ និងគ្រួសាររបស់គេ ដោយកសាងលំនៅដ្ឋាន មន្ទីរពេទ្យ វត្តអារាម សាលារៀន មណ្ឌលកំសាន្តលំហែកាយសម្រាប់ ពួកគេអោយបាន សមរម្យ ។

៧.៦ អនុវត្តការងារអាជីវកម្មតាមគំរោងផែនការដូចជា : ការកាប់ឆ្ការព្រៃ ការធ្វើផ្លូវ និងការប្រើប្រាស់ដី ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនិរន្តរភាពធនធានធម្មជាតិរបស់ទីតាំង និង ផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមក ពីការធ្វើអាជីវកម្ម-ផលិតកម្ម ។

៧.៧ រៀបចំធ្វើផលិតកម្ម - អាជីវកម្មតាមផែនការ ដូចមានចែងក្នុងរបាយការណ៍បច្ចេកទេសសេដ្ឋកិច្ចរបស់ខ្លួន និងដូចក្នុងប្រការ ៣ និងប្រការ ៧ នៃចំនុច ៧.៣ នៃកិច្ចសន្យានេះនៅលើផ្ទៃដីអាជីវកម្មជាក់ស្តែង ។

៧.៨ មានសិទ្ធិលក់ដូរប្រមូលទិញ បែងចែកចាតចែងផលិតផលគ្រប់ប្រភេទទាំងនៅក្នុង និងក្រៅប្រទេស តាមគោលការណ៍ និងច្បាប់ដែលជាធរមានក្នុងគោលដៅប្រើឱ្យការវិនិយោគខាងលើ ។

៧.៩ ចំពោះការនាំចូលទំនិញសំភារៈគ្រឿងចក្រ គ្រឿងបន្លាស់ វត្ថុធាតុដើម ដែលបម្រើឱ្យការធ្វើផលិតកម្ម - អាជីវកម្ម ពាក់ព័ន្ធ និងការបង់ពន្ធអាករផ្សេងៗ គឺអាស្រ័យដោយច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជាកំណត់ ។

៧.១០ ត្រូវអនុញ្ញាតអោយភាគី " ក " និង ស្ថាប័នពាក់ព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃសកម្មភាពរបស់ខ្លួនអំពីផលប៉ះពាល់បរិស្ថាន ។ ត្រូវអនុវត្តតាមការណែនាំរបស់ភាគី " ក " និង ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការពារបរិស្ថាន ។

៧.១១ ត្រូវធ្វើរបាយការណ៍អំពីលទ្ធផល នៃការអនុវត្តការងារវិនិយោគលើដីសម្បទានេះ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនភាគី " ក " ។

ប្រការ៨ : ការអនុញ្ញាតអោយសាងសង់

៨.១ ភាគី " ខ " មានសិទ្ធិធ្វើការអភិវឌ្ឍន៍រៀបចំសាងសង់សំណង់ និង ហេដ្ឋារចនាសម្ព័ន្ធនានាលើទីតាំងវិនិយោគដោយអនុលោមតាមប្លង់មេ និង គម្រោងអភិវឌ្ឍន៍ដែលមានការឯកភាពពីភាគី " ក " និង អនុវត្តតាមច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា និងសមស្របទៅនឹងទិសដៅការងារក្នុងប្រការ ៣ នៃកិច្ចសន្យានេះ ។

៨.២ រាល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា ទំនប់ ប្រឡាយ ដែលឱ្យអាចមានផលប៉ះពាល់ដល់តំបន់ ជុំវិញត្រូវមានការអនុញ្ញាតពីភាគី " ក " ឬស្ថាប័នពាក់ព័ន្ធ ។

ប្រការ៩ : សិទ្ធិនៃការគ្រប់គ្រង

រាល់អចលនៈទ្រព្យ និង ហេដ្ឋារចនាសម្ព័ន្ធព្រមទាំងសមិទ្ធិផលទាំងអស់ដែលបង្កើតឡើងដោយ ភាគី " ខ " ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី " ខ " រហូតដល់សុពលភាពនៃកិច្ចសន្យា ។

ប្រការ១០ : ការបញ្ចប់កិច្ចសន្យា

១០.១ ភាគី " ខ " មានសិទ្ធិដកហូតចេញពីគម្រោងការងារទាំងមូល ឬ ផ្នែកណាមួយ ក្នុងល័ក្ខខ័ណ្ឌមិនអាចគ្រប់គ្រងបានបន្ទាប់ពីបានការឯកភាពពីភាគី " ក " ។ ការដកត្រឡប់ទៅវិញ ឬ ការលក់សំភារៈបរិក្ខារពងចក្រនានានាំដាក់ម៉ាស៊ីន នាំវាដុកចំនិញ យានយន្តផ្សេងៗ និង ប្រដាប់ប្រដាព្រមទាំងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត និងគ្រឿងដាក់ភ្ជាប់នៅមួយកន្លែង ត្រូវធ្វើទៅតាមច្បាប់និងបទបញ្ញត្តិជាធរមាន ។

១០.២ ក្នុងករណីដែលភាគី " ខ " ដកខ្លួនដោយខ្លួនឯងនោះភាគី " ខ " ត្រូវទទួលខុសត្រូវតាមច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ។

១០.៣ ក្នុងករណីដែលភាគី " ខ " មិនបានចាប់ផ្តើមដំណើរការវិនិយោគដំបូង ដូចមានចែងក្នុងកិច្ចសន្យា ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះ រាជរដ្ឋាភិបាលមានសិទ្ធិបញ្ឈប់កិច្ចសន្យាដោយគ្មានល័ក្ខខ័ណ្ឌ និងគ្មានការសង នូវ ការខាតបង់ឡើយ ។ ការបញ្ឈប់បែបនេះនឹងនាំអោយមានការរឹបអូសប្រាក់កក់របស់ភាគី " ខ " ជាសម្បត្តិរដ្ឋ ។

១០.៤ ក្នុងករណីដែលពិនិត្យឃើញថា តំបន់ដីសម្បទាននេះមានធនធានរ៉ែ ដែលទនេសក្តានុពលសេដ្ឋកិច្ចខ្ពស់ ភាគី " ក " មានសិទ្ធិរំលាយកិច្ចសន្យាបន្ទាប់ពី បានចរចារជាមួយ ភាគី " ខ " ។

១០.៥ ក្នុងករណីដែលភាគី " ខ " មានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលលើសពី ០៦ (ប្រាំមួយ) ខែ ភាគី " ក " មានសិទ្ធិរំលាយកិច្ចសន្យាចោល ជាឯកតោភាគី ដោយគ្មានសំណង ។

ប្រការ១១ : វិវាទ និង ការដោះស្រាយ (អាជ្ញាកណ្តាល)

១១.១ ក្នុងករណីដែលមានវិវាទកើតក្នុងរយៈពេលនៃការអនុវត្តន៍កិច្ចសន្យានេះភាគីទាំងពីរ [illegible] ដោះស្រាយដោយយោងទៅតាមសិទ្ធិ និងភារកិច្ចរបស់ភាគីនីមួយៗដែលមានចែងក្នុងកិច្ចសន្យា [illegible] ។

១១.២ ក្នុងករណីដែលភាគីទាំងពីរមិនអាចសម្របសម្រួលឬ ដោះស្រាយវិវាទ [illegible] ត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជួយផ្សះផ្សាសម្រុះសម្រួល ។

១១.៣ ក្នុងករណីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅតែមិនអាចដោះស្រាយសម្រុះសម្រួលវិវាទនេះបានក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសំណើដូចមានចែងក្នុងចំណុចប្រការ ១១.២ ប្រការនេះទេ ភាគីទាំងពីរត្រូវបញ្ជូនសំណុំឯកសារនៃវិវាទនេះទៅតុលាការ នៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

ប្រការ១២ : ការទុកជាមិនបានការតែផ្នែកខ្លះ

ប្រសិនបើល័ក្ខខ័ណ្ឌណាមួយ នៃកិច្ចសន្យានេះត្រូវទុកជាមិនបានការ ឬគ្មានប្រសិទ្ធភាពផ្នែកផងទៃទៀតដែលនៅសល់ត្រូវមានសុពលភាព ដូចដែលមានសរសេរជាលាយល័ក្ខអក្សរចំពោះវិសាលភាពទាំងអស់ដែលច្បាប់បានអនុញ្ញាត ។

ប្រការ១៣ : ច្បាប់អភិបាល

ការព្រមព្រៀងនៃកិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ១៤ : ការព្រមព្រៀងទាំងស្រុង

ឯកសារនេះមានការព្រមព្រៀងទាំងស្រុងដោយភាគីទាំងពីរ និងជំនួសឱ្យទំនាក់ទំនងនិមិត្តរូប ឬការព្រមព្រៀងកន្លងមកទោះជាពាក្យសំដី ឬដោយលាយល័ក្ខអក្សរដែលជាប់ទាក់ទិននិងកិច្ចសន្យានេះឡើយ ។ កិច្ចសន្យានេះមិនអាចកែប្រែ ឬផ្លាស់ប្តូរបានទេលើកលែងតែមានសរសេរជា លាយល័ក្ខអក្សរដោយមានចុះហត្ថលេខា និងទទួលស្គាល់ដោយភាគី ទាំងពីរ ។

ប្រការ១៥ : ករណីប្រធានសក្តិ

ក្នុងព្រឹត្តិការណ៍ដែលភាគី " ខ " មិនអាចបំពេញការហើយកិច្ចរបស់ខ្លួនជាផ្នែកឬទាំងស្រុងបានអនុលោមទៅតាមល័ក្ខខ័ណ្ឌផ្សេងៗ នៃកិច្ចសន្យានេះដោយសារតែករណីប្រធានសក្តិ ភាគី " ខ " ត្រូវប្រកាសប្រាប់ ភាគី " ក " ដោយសរសេរជាលាយល័ក្ខអក្សរបញ្ជាក់ពីហេតុផលរបស់ខ្លួន ហើយកាតព្វកិច្ចរបស់ភាគី " ខ " នឹងត្រូវបញ្ឈប់ជាបណ្តោះអាសន្នក្នុងកំឡុងពេលនៃរយៈពេល ដែលជាប់ពាក់ព័ន្ធនោះ ។

ពាក្យ: " ករណីប្រធានសក្តិ " រួមមានភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាម រញ្ជួយផែនដី ការរំលើបរំលួលនៃផ្នែក ស៊ីវិលសកម្មភាពការបះបោរ កុប្បកម្ម ការផ្ទុះផ្សេងៗ ការឆ្លងរាលដាលនៃជំងឺផ្សេងៗ ព្រមទាំងព្រឹត្តិការណ៍ ឬកាលៈទេសៈផ្សេងៗ ទៀតដែលហួសពីការគ្រប់គ្រងសមស្របរបស់ភាគីទាំងពីរ ។

ប្រការ១៦ : សិទ្ធិលើធនធានធម្មជាតិ និង កេរដំណែល

១៦.១ មុនពេលកាប់ឆ្ការដីសម្រាប់អភិវឌ្ឍន៍ភាគី " ខ " ត្រូវសុំការយល់ព្រមពីភាគី " ក " ក្នុងការកាប់រំលំរុក្ខជាតិ និង ដឹកជញ្ជូនឈើដែលមានលើដីនោះ និង ត្រូវបង់ថ្លៃសួយសារនិងបុព្វលាភជូនភាគី " ក " ដោយអនុលោមតាមបទប្បញ្ញត្តិ និង ច្បាប់ស្តីពីព្រៃឈើជាធរមាន ។

១៦.២ ធនធានរ៉ែ ឬ វត្ថុដែលជាកេរដំណែលវប្បធម៌របស់ជាតិនៅលើដី ឬ ក្រោមដីជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ នៅក្នុងការកាប់គាស់ដីសម្រាប់ធ្វើផលិតកម្ម-កសិឧស្សាហកម្ម បើភាគី "ខ" រកឃើញធនធានរ៉ែ ឬ វត្ថុដែលជាកេរដំណែលវប្បធម៌របស់ជាតិនៅលើដី ឬក្រោមដី ភាគី "ខ" ត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួន ហើយរាយការណ៍ជាបន្ទាន់ជូនភាគី "ក" ។

១៦.៣ ក្នុងករណីដែលសិក្សាស្រាវជ្រាវឃើញថាតំបន់សម្បទាននេះមានធនធានរ៉ែដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ដោយមានការបញ្ជាក់ពីស្ថាប័នជំនាញ ភាគី "ក" មានសិទ្ធិកាត់តំបន់ជម្រករ៉ែចេញពីតំបន់សម្បទាន ដោយផ្នែក ឬទាំងស្រុង ។

ប្រការ១៧ : ភាសា

កិច្ចសន្យានេះធ្វើនៅរាជធានីភ្នំពេញ ជាភាសាខ្មែរចំនួន ២០ ច្បាប់ និង ភាសាអង់គ្លេស ២០ ច្បាប់ ហើយច្បាប់ នីមួយៗ មាន តម្លៃស្មើៗគ្នា ។ ក្នុងករណីខ្វែងគំនិតគ្នាលើការបកស្រាយកិច្ចសន្យាភាសាខ្មែរត្រូវយកជាមូលដ្ឋាន ។

ប្រការ១៨ : ការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី...១៤... ខែ...កក្កដា...ឆ្នាំ ២០០៧ ហើយត្រូវផុតកំណត់នៅថ្ងៃទី...១៧... ខែ...កក្កដា...ឆ្នាំ ២០៧៧... ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....១៤.....ខែកក្កដា ឆ្នាំ ២០០៧

តំណាងភាគី "ខ"

ប្រធាន ជនីសាយហ្គន_បិញ្ញាហ្វើត (ខេមរ ឌី ខេ)

ចិន ចាន់តាំ

តំណាងភាគី "ក"

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់ សារុន

កន្លែងចំលងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងបរិស្ថាន
- សាលាខេត្តក្រចេះ
- រដ្ឋបាលព្រៃឈើ
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- នាយកដ្ឋាន[illegible]
- នាយកដ្ឋានកសិ-ឧស្សាហកម្ម
- នាយកដ្ឋានទីផ្សារកសិកម្ម
- មន្ទីរកសិកម្មខេត្តក្រចេះ
- ភាគី "ក"
- ភាគី "ខ"
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ៣៧៩ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ជំរាបជូន
ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្មវត្ថុ : ករណីសំណើសុំដីសម្បទានចំនួន ១០ ០០០ ហិកតា របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សំរាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ ។

យោង : -លិខិតលេខ ១៤៣៧ កសក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូន ឯកឧត្តមមេត្តាជ្រាបថា : ចំពោះសំណើសុំដីសម្បទានចំនួន ១០ ០០០ ហិកតា របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សំរាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ នោះ រាជរដ្ឋាភិបាលបានសំរេចដូចខាងក្រោម :

១. យល់ព្រមផ្តល់ដីសម្បទានសេដ្ឋកិច្ចជូនក្រុមហ៊ុននេះ ចំនួន ៦.៤៣៦ ហិកតា ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ ។

២. ក្រុមហ៊ុនត្រូវសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នមានសមត្ថកិច្ច ចុះពិនិត្យដីធ្លីដែលពាក់ព័ន្ធ និងផ្ទៃដីព្រៃឈើដែលត្រូវរក្សាទុក ដើម្បីជៀសវាងការប៉ះពាល់ផ្ទៃដីប្រជាពលរដ្ឋ និងផ្ទៃដីតំបន់ការពារផ្សេងៗ ។ ក្រុមហ៊ុនត្រូវចុះកិច្ចសន្យាវិនិយោគជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣. មុនការចាប់ផ្តើមឈូសឆាយធ្វើអាជីវកម្ម ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនឹងត្រូវធ្វើការចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋឱ្យបានច្បាស់លាស់ ។

៤. ការវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី ក្រុមហ៊ុនត្រូវមានផែនការមេ និងផែនការអនុវត្តប្រចាំឆ្នាំ ដោយទទួលស្គាល់ពីស្ថាប័នជំនាញ និងមានការចូលរួមគាំទ្រពីអាជ្ញាធរ និងសហគមន៍ពលរដ្ឋនៅមូលដ្ឋាន ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

ចម្លងជូន :
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលាខេត្ត ក្រចេះ
-រដ្ឋបាលព្រៃឈើ
-ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd
-ឯកសារ-កាលប្បវត្តិ

ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប្រាក់ សុខុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
[illegible]

ភ្នំពេញ, ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៧

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូន ឯកឧត្តម ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទាន ចំនួន ៦.៤៣៦ ហិកតា ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ សំរាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ជាមួយក្រុមហ៊ុន ដូទឺសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd ។

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខាលើសិទ្ធិប្រទាននេះ ដើម្បីជាសក្ខីភាពចំពោះការប្រគល់សិទ្ធិប្រទានជូនឯកឧត្តម ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

Phnom Penh, April 04 2007

DELEGATION OF FULL POWERS

- Considering the Constitution of the Kingdom of Cambodia;
- Considering the Royal Decree NS/RKT/0704/124 dated 15 of July 2004 on the Nomination of the Royal Government of Cambodia;
- Considering the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers;
- Pursuant to the proposal of the Minister of Agriculture, Forestry and Fisheries;

THE ROYAL GOVERNMENT

Delegates herewith to His Excellency Mr. CHAN SARUN, Minister of Agriculture, Forestry and Fisheries, the full powers to sign the contract with DAU TU SAIGON-BINH PHUOC (SBK) Co., Ltd on the land concession of 6,436 hectares in They commune and Kantuot commune, Kratie district of Kratie province for the plantation of Rubber, Manioc, Cashew nut and the construction of processing factory.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៤៣៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ២០០៦

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សូមគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់

កម្មវត្ថុ :ករណីសំណើសុំដីសម្បទានចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ ។

យោង : ពាក្យសុំវិនិយោគសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd. ។

ជូនភ្ជាប់:-កំណត់ហេតុចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពី លទ្ធផលនៃការចុះសិក្សាវាយតម្លៃលើសំណើសុំសម្បទានដីសេដ្ឋកិច្ច របស់ក្រុមហ៊ុនដូទីសាយ ហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ , DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ .... ចំនួន ០១ច្បាប់ ។

-ផែនទីទីតាំងដីស្នើសុំវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ចំនួន ០១ច្បាប់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា: ចំពោះសំណើសុំដីសម្បទានចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានចាត់ក្រុមលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច សហការជាមួយអាជ្ញាធរដែនដី និងជំនាញមូលដ្ឋាន ចុះសិក្សាជាក់ស្តែងដល់ទីតាំងស្នើសុំវិនិយោគ ដែលទទួលបានលទ្ធផលដូចខាងក្រោម :

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៤៣៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០០

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សូមគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់

កម្មវត្ថុ :ករណីសំណើសុំដីសម្បទានចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ ។

យោង : ពាក្យសុំវិនិយោគសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd. ។

ជូនភ្ជាប់:-កំណត់ហេតុចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពី លទ្ធផលនៃការចុះសិក្សាវាយតម្លៃលើសំណើសុំសម្បទានដីសេដ្ឋកិច្ច របស់ក្រុមហ៊ុនដូទីសាយ ហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ , DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ .... ចំនួន ០១ច្បាប់ ។

-ផែនទីទីតាំងដីស្នើសុំវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ចំនួន ០១ច្បាប់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា: ចំពោះសំណើសុំដីសម្បទានចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) DAU TU SAIGON-BINH PHUOC (SBK) Co., Ltd សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានចាត់ក្រុមលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច សហការជាមួយអាជ្ញាធរដែនដី និងជំនាញមូលដ្ឋាន ចុះសិក្សាជាក់ស្តែងដល់ទីតាំងស្នើសុំវិនិយោគ ដែលទទួលបានលទ្ធផលដូចខាងក្រោម :

-ទីតាំងផ្ទៃដីដែលក្រុមហ៊ុនស្នើសុំ អាចមានលទ្ធភាពដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទីបាន ដែលគួរអនុញ្ញាតជាគោលការណ៍លើផ្ទៃដីចំនួន ៦.៤៣៦ ហិកតា ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ វិនិយោគតាមរូបភាពសម្បទានដីសេដ្ឋកិច្ច ។

